**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៚៚៙៙

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខ: ៧៦០ ប្រក.សក.ដជគ

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងគ្រប់គ្រងក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុន និងការផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-**

នីតិបុគ្គល សំដៅលើក្រុមហ៊ុន ឬសហគ្រាសដែលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈដោយប្រើប្រាស់រថយន្តក្រុង។

**ប្រការ ៥.-**

ក្រុមហ៊ុនដែលមានបំណងធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង និងសៀវភៅប្រតិបត្តិការអាជីវកម្មតាមខ្សែរត់ពីក្រសួងសាធារណការនិងដឹកជញ្ជូន។

សៀវភៅប្រតិបត្តិការអាជីវកម្មតាមខ្សែរត់មានចែងនៅក្នុង **ឧបសម្ព័ន្ធទី១**។

**ប្រការ ៦.-**

ក្រុមហ៊ុនឬតំណាងស្របច្បាប់ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងនិងលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកឬតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលមានគេហទំព័រ transportlicense.mpwt.gov.kh របស់ក្រសួងសាធារណការនិងដឹកជញ្ជូនតាមគំនូសបំព្រួញដូចមានចែងក្នុង **ឧបសម្ព័ន្ធទី២** និងដោយភ្ជាប់សំណុំឯកសារដូចខាងក្រោម៖

**ក.** វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង៖

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
  - លិខិតឆ្លងដែន(ករណីម្ចាស់ក្រុមហ៊ុនមានសញ្ជាតិបរទេស)
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- ប័ណ្ណប៉ាតង់
- តារាងស្ថិតិរថយន្ត
- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត(ដេប៉ូ)

ទម្រង់នៃពាក្យសុំចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្ម មានចែងក្នុង **ឧបសម្ព័ន្ធទី៣**។

**ខ.** លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង៖

- អត្តសញ្ញាណរបស់ប្រធានក្រុមហ៊ុន៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
  - លិខិតឆ្លងដែន(ករណីម្ចាស់ក្រុមហ៊ុនមានសញ្ជាតិបរទេស)
- សៀវភៅប្រតិបត្តិការអាជីវកម្ម
- វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- តារាងស្ថិតិរថយន្ត
- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត (ដេប៉ូ)

ទម្រង់នៃពាក្យសុំលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មមានចែងក្នុង **ឧបសម្ព័ន្ធទី៤**។

**ប្រការ ៧.-**

សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន និងលិខិតអនុញ្ញាតឱ្យក្រុមហ៊ុន៖

- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង មានសុពលភាពអចិន្ត្រៃយ៍
- លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង មានសុពលភាព៥(ប្រាំ)ឆ្នាំ។

**ប្រការ ៨.-**

ក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវផ្តល់របាយការណ៍អំពីទិន្នផលនៃការដឹកជញ្ជូននៅរៀងរាល់ខែ តាមទម្រង់ **ឧបសម្ព័ន្ធទី៥** និងតាមគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**ប្រការ ៩.-**

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង និងលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវបានព្យួរនិងអស់សុពលភាពដោយស្វ័យប្រវត្តិក្នុងករណីដូចខាងក្រោម៖

**ក.** ករណីព្យួរ

លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវបានព្យួរមិនឱ្យធ្វើអាជីវកម្មក្នុងរយៈពេល ៣ខែ ឬ៦ខែ ក្នុងករណីដែលក្រុមហ៊ុនមិនបានគោរពតាមលក្ខខណ្ឌ និងគោលការណ៍ណែនាំរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនដូចមានចែងក្នុងឧបសម្ព័ន្ធទី១។

**ខ.** ករណីអស់សុពលភាព

- សាលក្រមតុលាការបានសម្រេចហាមឃាត់ការធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងរបស់ក្រុមហ៊ុន
- ក្រុមហ៊ុនក្ស័យធន
- ក្រុមហ៊ុនត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម
- លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង អស់សុពលភាព
- ក្រុមហ៊ុនបានផ្អាកប្រតិបត្តិការលើសពី១៥ថ្ងៃនៃថ្ងៃធ្វើការដោយពុំបានជូនដំណឹងមកក្រសួងជាមុន។

**ប្រការ ១០.-**

ក្រុមហ៊ុនត្រូវមកបន្តលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង យ៉ាងតិច៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការមុនផុតសុពលភាព។ ក្នុងករណីក្រុមហ៊ុនមានមូលហេតុសមស្របក្នុងការផ្អាកធ្វើអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនត្រូវយកឯកសារមកតម្កល់នៅអគ្គនាយកដ្ឋានដឹកជញ្ជូនបាន៦០(ហុកសិប)ថ្ងៃចាប់ពីថ្ងៃផ្អាកប្រតិបត្តិការ។

**ប្រការ ១១.-**

សំណុំឯកសារនៃវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍ នៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

សំណុំឯកសារនៃលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវតម្កល់ទុកយ៉ាងតិច៦(ប្រាំមួយ)ឆ្នាំ នៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**ប្រការ ១២.-**

ក្រុមហ៊ុនដែលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងត្រូវសហការរៀបចំស្ថានីយអ្នកដំណើរនិងចំណតរង់ចាំ លើគម្រោងខ្សែរត់របស់រថយន្តដឹកជញ្ជូនសាធារណៈស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ ១៣.-**

ការសុំផ្តល់វិញ្ញាបនបត្រចុះបញ្ជីធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ការសុំផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ ១៤.-**

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកត្រូវគ្រប់គ្រង តាមដាន ត្រួតពិនិត្យ ណែនាំនិងវាយតម្លៃលើការអនុវត្តរបស់ក្រុមហ៊ុនឱ្យស្របតាមសៀវភៅប្រតិបត្តិការអាជីវកម្មដែលបានកំណត់ឱ្យប្រើប្រាស់។

**ប្រការ ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៦.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានជំនាញ ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី-ខេត្ត ប្រធានអង្គភាពក្រោមឱវាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួន តាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ..............ខែ..............ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី......ខែ..........ឆ្នាំ ២០១៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត

"ដើម្បីជូនជ្រាប"
- ដូចប្រការ១៦

"ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការនិងដឹកជញ្ជូន
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
លេខ៖.......................សក.ដជគ

# ឧបសម្ព័ន្ធទី១

## សៀវភៅប្រតិបត្តិការ
## អាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង
## លើខ្សែរត់.........

(ចាប់ពី.................... ដល់..................)

ក្រុមហ៊ុន..............................................................

« ............. »

[ ស្លាកសញ្ញាក្រុមហ៊ុន ]

ឆ្នាំ ២០.......

# មាតិកា


| | | ទំព័រ |
|---|---|---|
| **ជំពូក ១** | **បេសកកម្ម និងវិសាលភាពប្រតិបត្តិការរបស់ក្រុមហ៊ុន** | ១ |
| | - ផ្នែកទី១ បេសកកម្ម | ១ |
| | - ផ្នែកទី២ វិសាលភាពប្រតិបត្តិការ | ២ |
| **ជំពូក ២** | **ការគ្រប់គ្រងអាជីវកម្ម** | ២ |
| | - ផ្នែកទី១ កាតព្វកិច្ចទូទៅរបស់ក្រុមហ៊ុន | ២ |
| | - ផ្នែកទី២ ការគ្រប់គ្រងរថយន្ត អ្នកបើកបរ បុគ្គលិកបម្រើសេវា និងអ្នកដំណើរ | ៣ |
| | - ផ្នែកទី៣ ពេលវេលាប្រតិបត្តិការ | ៦ |
| | - ផ្នែកទី៤ ខ្សែរត់ និងចំណត | ៦ |
| | - ផ្នែកទី៥ គោលនយោបាយ និងតម្លៃសំបុត្រ | ៧ |
| | - ផ្នែកទី៦ ការជួសជុល ថែទាំទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារ | ៨ |
| **ជំពូក ៣** | **ការត្រួតពិនិត្យ និងការគ្រប់គ្រង** | ៩ |
| | - ផ្នែកទី១ បទប្បញ្ញត្តិទូទៅ | ៩ |
| | - ផ្នែកទី២ ការទទួលខុសត្រូវរបស់ក្រុមហ៊ុន | ៩ |
| **ជំពូក ៤** | **ការដោះស្រាយវិវាទ** | ៩ |
| **ជំពូក ៥** | **អវសានបញ្ញត្តិ** | ៩ |

# សៀវភៅប្រតិបត្តិការ
# អាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង
# លើខ្សែរត់......(ចាប់ពី......... ដល់............)

## នាមនិងទម្រង់គតិយុត្តរបស់ក្រុមហ៊ុន

ក្រុមហ៊ុន.............................................. ហៅកាត់ថា «......»មានបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ.................. ចុះថ្ងៃទី......... ខែ......... ឆ្នាំ.......... របស់ក្រសួងពាណិជ្ជកម្ម។
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងលេខ.................. ចុះថ្ងៃទី......... ខែ......... ឆ្នាំ.......... របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

សៀវភៅប្រតិបត្តិការអាជីវកម្មនេះកំណត់បេសកកម្ម វិធានប្រតិបត្តិការ ការគ្រប់គ្រង កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ក្រុមហ៊ុន«......» ដែលបានឯកភាពពីអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

## ជំពូក ១
## បេសកកម្ម និងវិសាលភាពប្រតិបត្តិការរបស់ក្រុមហ៊ុន
### ផ្នែកទី ១ បេសកកម្ម

១- ក្រសួងសាធារណការនិងដឹកជញ្ជូន ប្រគល់ជូន «......» នូវបេសកកម្មដូចខាងក្រោម៖

- ធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង (Bus) ក្នុងគោលដៅដើម្បីផ្តល់ប្រយោជន៍ដឹកជញ្ជូនសាធារណៈដល់ប្រជាពលរដ្ឋរួមមាន៖
  - ផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរ
  - ធានាសុវត្ថិភាព
  - ចំណេញពេលវេលា
  - សន្សំថវិកា
  - កាត់បន្ថយការប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន
  - កាត់បន្ថយការកកស្ទះចរាចរណ៍
  - កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
  - កាត់បន្ថយការប្រើប្រាស់ថាមពលខ្ជះខ្ជាយ
  - កាត់បន្ថយការបំពុលបរិស្ថាន
  - កាត់បន្ថយផលប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋ
  - បង្កើនភាពស៊ីវិល័យក្នុងការទាក់ទាញភ្ញៀវទេសចរណ៍។ល។
- គ្រប់គ្រងយានយន្តដឹកជញ្ជូនសាធារណៈ (Bus) និងបណ្តាញខ្សែរត់
- រៀបចំគោលនយោបាយតម្លៃសំបុត្រនិងម៉ោងពេលប្រតិបត្តិការដឹកជញ្ជូន
- រៀបចំឱ្យមានស្ថានីយរថយន្តក្រុង ស្ថានីយចំណតរថយន្តក្រុង និងចំណតរង់ចាំ។ល។

២- ក្រុមហ៊ុនត្រូវធ្វើប្រតិបត្តិការអាជីវកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិដែលនៅជាធរមានធ្វើយ៉ាងណាធានាឱ្យដំណើរការរបស់ក្រុមហ៊ុនប្រព្រឹត្តទៅរលូន ព្រមទាំងអាចផ្តល់ជូននូវតម្រូវការរបស់ប្រជាពលរដ្ឋបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ផ្នែកទី ២ វិសាលភាពប្រតិបត្តិការ

៣- ក្រុមហ៊ុនត្រូវបានប្រគល់សិទ្ធិឱ្យធ្វើអាជីវកម្មនិងគ្រប់គ្រងសេវាកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង (Bus) នៅតាមគម្រោងខ្សែរត់ដែលត្រូវបានកំណត់។ ប្លង់ទីតាំងទីស្នាក់ការផែនទីបណ្តាញខ្សែរត់ ប្លង់ទីតាំងចំណត ស្ថានីយចំណត (Terminal) ចំណតរង់ចាំ (Bus Stop) និងប្រភេទរថយន្តក្រុង (Bus) ដែលបានអនុញ្ញាតឱ្យចរាចរណ៍ត្រូវបានកំណត់និងភ្ជាប់នៅក្នុងសៀវភៅប្រតិបត្តិការអាជីវកម្មនេះ។

## ជំពូក ២
## ការគ្រប់គ្រងអាជីវកម្ម
## ផ្នែកទី១ ភារកិច្ចទូទៅរបស់ក្រុមហ៊ុន

៤- ក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងត្រូវធានានិរន្តរភាពនៃការដឹកជញ្ជូន គុណភាពសេវាកម្ម ការគោរពពេលវេលាឱ្យបានទៀងទាត់ និងជាពិសេសការផ្តល់អាទិភាពចំពោះអ្នកដំណើរដែលជាកុមារ ស្ត្រីមានផ្ទៃពោះ ជនពិការ និងចាស់ជរា។

៥- ក្រុមហ៊ុនត្រូវអនុវត្តទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំផ្សេងៗរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសត្រូវពង្រឹងសកម្មភាពត្រួតពិនិត្យរាល់ដំណើរការប្រតិបត្តិការអាជីវកម្មរបស់ខ្លួន តាមគ្រប់មធ្យោបាយដែលមិនប៉ះពាល់ដល់ប្រយោជន៍អ្នកធ្វើដំណើរ ។

៦- ក្រុមហ៊ុនត្រូវអនុវត្តនូវរាល់លក្ខខណ្ឌដែលបានកំណត់នៅក្នុងសៀវភៅប្រតិបត្តិការអាជីវកម្មនេះ មានជាអាទិ៍៖

- នៅពេលចាប់ផ្តើមធ្វើអាជីវកម្ម ក្រុមហ៊ុនត្រូវរៀបចំទីតាំងស្ថានីយចំណត និងស្ថានីយរថយន្តចេញដំណើរឱ្យបានសមស្របទៅតាមបទដ្ឋានផ្សេងៗ ដែលមិនបណ្តាលឱ្យប៉ះពាល់ដល់លំហូរចរាចរណ៍នៅលើដងផ្លូវ និងដែលនាំឱ្យបាត់បង់សោភ័ណភាពទីក្រុង។
- ក្រុមហ៊ុនត្រូវសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងមន្ទីរជំនាញពាក់ព័ន្ធក្នុងការរៀបចំផែនទីខ្សែរត់ ស្ថានីយចេញដំណើរ ស្ថានីយមកដល់ និងចំណតរង់ចាំនៅតាមដងផ្លូវ ឬទីសាធារណៈ។
- នៅតាមចំណតស្ថានីយរថយន្តចេញដំណើរនិងស្ថានីយមកដល់នីមួយៗ ក្រុមហ៊ុនត្រូវរៀបចំបញ្ជរលក់សំបុត្រ និងកន្លែងរង់ចាំ ហើយត្រូវរៀបចំឱ្យមានសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យដែលនឹងមិនប៉ះពាល់ដល់បរិស្ថាននៅជុំវិញនិងនៅក្នុងតំបន់។
- ក្រុមហ៊ុនត្រូវរៀបចំស្លាកសញ្ញាឬភ្លើងសញ្ញាផ្តល់ព័ត៌មានអំពីតម្លៃសំបុត្រ ពេលវេលាចេញដំណើរ និងពេលវេលាមកដល់ នៅតាមបណ្តាស្ថានីយចេញដំណើរឬស្ថានីយមកដល់ ដែលមានទីតាំងនៅតាមទីសាធារណៈ ឬតាមដងផ្លូវដើម្បីបង្កភាពងាយស្រួលដល់អ្នកដំណើរ។
- ក្រុមហ៊ុនត្រូវរៀបចំកាលវិភាគនៃពេលវេលាចេញដំណើរ និងពេលវេលាមកដល់នៃរថយន្តនីមួយៗនៅតាមបណ្តាស្ថានីយនិងចំណតរង់ចាំ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែង។
- ក្រុមហ៊ុនត្រូវបណ្តុះបណ្តាលអំពីច្បាប់ចរាចរណ៍ផ្លូវគោកនិងច្បាប់ផ្លូវថ្នល់ ដល់អ្នកបើកបររថយន្តក្រុង
- ក្រុមហ៊ុនធ្វើការអប់រំនិងណែនាំជាប្រចាំ ពិសេសត្រូវផ្តល់ឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនដល់អ្នកបើកបររថយន្តក្រុង ។
- ក្រុមហ៊ុនត្រូវយកកម្រៃសេវាដឹកជញ្ជូនអ្នកដំណើរ ទៅតាមការកំណត់ក្នុងសៀវភៅប្រតិបត្តិការអាជីវកម្មនេះ។ ក្នុងករណីក្រុមហ៊ុនមានបំណងធ្វើការផ្លាស់ប្តូរនូវកម្រៃសេវាដឹកជញ្ជូនអ្នកដំណើរ ក្រុមហ៊ុនត្រូវធ្វើការជូនដំណឹងមកក្រសួងសាធារណការនិងដឹកជញ្ជូនជាមុន និងត្រូវរង់ចាំការសម្រេចពីក្រសួង។
- ក្រុមហ៊ុនត្រូវផ្តល់ជូនព័ត៌មានដល់អ្នកធ្វើដំណើរនូវលក្ខខណ្ឌមួយចំនួនដូចជា សំបុត្រដែលលក់ចេញ ឬកាក់ដែលបង់រួច ឬកាតដែលបានឆូតគឺមិនអាចបង្វិលជាប្រាក់គ្រលប់វិញ។

- ក្រុមហ៊ុនត្រូវបិតនៅផ្នែកណាមួយនៃរថយន្តដែលអាចឱ្យអ្នកធ្វើដំណើរបានឃើញនូវ
  - តារាងតម្លៃសេវាដឹកជញ្ជូន
  - ឈ្មោះនិងរូបថតអ្នកបើកបរ
  - ឈ្មោះនិងរូបថតបុគ្គលផ្តល់សេវាលើរថយន្ត
  - ព័ត៌មានសំខាន់ៗផ្សេងទៀត ដែលអ្នកធ្វើដំណើរមានសិទ្ធិទទួលបាន។
- រៀបចំនូវយន្តការ ឬនីតិវិធីទទួលសេចក្តីរាយការណ៍ ឬបណ្តឹងរបស់អ្នកធ្វើដំណើរ ដែលទទួលរងផលប៉ះពាល់ដល់ប្រយោជន៍ពីសកម្មភាព ឬទង្វើអវិជ្ជមានរបស់អ្នកបើកបររថយន្ត ឬរបស់អ្នកផ្តល់សេវាលើរថយន្ត ឬបុគ្គលិករបស់ក្រុមហ៊ុន
- ក្រុមហ៊ុនត្រូវទទួលខុសត្រូវរាល់ព្យសនកម្មដែលបណ្តាលឱ្យខូចប្រយោជន៍របស់អ្នកធ្វើដំណើរ ឬបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌ និងលិខិតបទដ្ឋានផ្សេងទៀតដែលនៅជាធរមាន។
- រាល់ការផ្សព្វផ្សាយពាណិជ្ជកម្មឬការបិទផ្សាយខ្លឹមសារផ្សេងៗនៅលើរថយន្តក្រុង ឬនៅតាមស្ថានីយផ្សេងៗ ក្រុមហ៊ុនត្រូវពិនិត្យនិងឯកភាពលើអត្ថន័យនិងខ្លឹមសារនៃអត្ថបទ ឬរូបភាពនៃការផ្សព្វផ្សាយនោះជាមុន
- ក្នុងករណីក្រុមហ៊ុនមានបំណងស្នើសុំកែប្រែលក្ខខណ្ឌណាមួយខាងលើ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំទៅក្រសួងសាធារណការនិងដឹកជញ្ជូន។ ក្រសួងសាធារណការនិងដឹកជញ្ជូនមានសិទ្ធិអនុញ្ញាត ឬមិនអនុញ្ញាតឱ្យធ្វើការកែប្រែលក្ខខណ្ឌខាងលើ ។

## ផ្នែកទី២ ការគ្រប់គ្រងរថយន្ត អ្នកបើកបរ បុគ្គលិកបម្រើសេវា និងអ្នកដំណើរ

៧- ក្រុមហ៊ុនអាចប្រើប្រាស់រថយន្តដឹកអ្នកដំណើរគ្រប់ប្រភេទសម្រាប់ដំណើរការដឹកជញ្ជូនសាធារណៈទៅតាមតម្រូវការជាក់ស្តែងដែលត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវមានលក្ខខណ្ឌសារវន្តមួយចំនួនដូចខាងក្រោម៖

**ក. លក្ខខណ្ឌរបស់រថយន្ត៖**

- ជារថយន្តចង្កូតឆ្វេង
- ជាប្រភេទរថយន្តដឹកអ្នកដំណើរ
- ជារថយន្តមានរយៈពេលប្រើប្រាស់មិនលើសពី ២០ ឆ្នាំ គិតចាប់ពីឆ្នាំផលិត
- ជារថយន្តមានចំនួនកៅអីនិងចំណុះផ្ទុក ត្រឹមត្រូវតាមស្ថានភាពជាក់ស្តែង
- ជារថយន្តប្រភេទម៉ាស៊ីនស្តង់ដារបច្ចេកទេសចាប់ពី EURO II ឡើង
- ជារថយន្តមានម៉ាស៊ីនត្រជាក់និងឧបករណ៍បរិក្ខារផ្សេងៗទៀត ប្រកបដោយសុវត្ថិភាពនិងផាសុកភាព
- ជារថយន្តមានកៅអីឬទីតាំងសម្រាប់ជនអាទិភាពដូចជា៖ ស្ត្រីមានផ្ទៃពោះ ជនពិការ និងចាស់ជរា
- ជារថយន្តមានបំពាក់ស្លាកសញ្ញាសម្គាល់រថយន្តក្រុង ពណ៌ លេខរៀង និងលេខទូរស័ព្ទទំនាក់ទំនង។

**ខ. បែបបទត្រូវបំពេញ**

- រថយន្តត្រូវមានបណ្ណសម្គាល់យានយន្ត ផ្លាកលេខ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ
- លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូន និងប្រការផ្សេងៗទៀតដោយអនុលោមទៅតាមច្បាប់ចរាចរណ៍ផ្លូវគោក
- រថយន្តត្រូវមានលិខិតធានារ៉ាប់រងរថយន្ត
- រថយន្តត្រូវមាននូវលិខិតអនុញ្ញាតផ្សេងៗទៀត ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច។

**គ. សញ្ញាសម្គាល់រថយន្តក្រុង និងបរិក្ខារបំពាក់បន្ថែម**

- ត្រូវមានសញ្ញា( LOGO) សម្គាល់រថយន្តក្រុង លេខទូរស័ព្ទ និងលេខរៀងរថយន្ត
- ផ្លាកសញ្ញាសម្គាល់រថយន្តក្រុងត្រូវមានអក្សររត់និងភ្លើងបំភ្លឺនៅលើដំបូលរបស់រថយន្ត។

៨- ក្រុមហ៊ុនត្រូវរៀបចំឱ្យមាននូវបទបញ្ជា និងលក្ខខណ្ឌសម្រាប់អ្នកបើកបរដោយតម្រូវឱ្យបំពេញនូវលក្ខខណ្ឌសារវន្តមួយចំនួនដូចខាងក្រោម៖

+ អ្នកបើកបរត្រូវ៖

- មានបណ្ណបើកបរ(នៅសុពលភាព)តាមប្រភេទរថយន្តដែលចេញឱ្យដោយក្រសួងសាធារណការនិងដឹកជញ្ជូន
- មានកាយសម្បទាមាំមួន និងមានសុខភាពល្អ
- បានត្រួតពិនិត្យជាតិអាល់កុលនិងសារធាតុញៀន មុននិងក្រោយការបើកបរ
- មានអត្តចរិតស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់ចំពោះអ្នកដំណើរ
- ប្រើប្រាស់ឯកសណ្ឋានផ្លូវការ និងបណ្ណសម្គាល់ខ្លួនរបស់ក្រុមហ៊ុន នៅពេលបំពេញការងារ
- គោរពពេលវេលា និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន
- រក្សាទុករាល់សម្ភាររបស់អ្នកដំណើរដែលភ្លេចនៅលើរថយន្ត និងត្រូវប្រគល់សម្ភារទាំងនោះទៅទីស្នាក់ការកណ្ដាលដើម្បីរង់ចាំប្រគល់ជូនម្ចាស់ដើមវិញ
- គោរពនិងអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ចរាចរណ៍ផ្លូវគោក និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលនៅជាធរមាន។

+ អ្នកបើកបរមិនត្រូវ៖

- ផ្ទុកទំនិញនិងចំនួនមនុស្សលើសកម្រិតកំណត់របស់រថយន្ត
- ទាមទារតម្លៃសេវាដឹកជញ្ជូនលើសការកំណត់ក្នុងសៀវភៅប្រតិបត្តិការអាជីវកម្មនេះ
- បើកហួសល្បឿនកំណត់ដែលមានចែងនៅក្នុងច្បាប់ចរាចរណ៍ផ្លូវគោក
- សេពគ្រឿងស្រវឹងនិងគ្រឿងញៀន ទោះបីស្ថិតក្នុងស្ថានភាពណាក៏ដោយ
- ដឹកជញ្ជូនទំនិញគ្រោះថ្នាក់ អាវុធ ជាតិផ្ទុះ និងសារធាតុផ្សេងៗ ដែលច្បាប់បានហាមឃាត់
- បង្កហេតុនិងសកម្មភាពអវិជ្ជមានផ្សេងៗដែលអាចបណ្ដាលឱ្យប៉ះពាល់ដល់អ្នកធ្វើដំណើរ ឬទ្រព្យសម្បត្តិរដ្ឋ។

+ អ្នកបើកបរមានសិទ្ធិ៖

- ណែនាំដល់អ្នកដំណើរឱ្យរក្សារបៀបរៀបរយ និងសណ្ដាប់ធ្នាប់នៅក្នុងរថយន្ត
- ហាមឃាត់អ្នកធ្វើដំណើរដែលមិនស្ដាប់ ឬមិនអនុវត្តតាមការណែនាំ
- ហាមឃាត់អ្នកដំណើរដែលមានទង្វើផ្ទុយពីបទបញ្ជា ឬលក្ខខណ្ឌអនុញ្ញាត
- មិនអនុញ្ញាតឱ្យធ្វើដំណើរ នូវអ្នកដំណើរដែល៖
  - គ្មានសម្លៀកបំពាក់ ឬសម្លៀកបំពាក់មិនសមរម្យ
  - កុមារក្រោមអាយុ៦ឆ្នាំ (គ្មានអាណាព្យាបាលនៅជាមួយ)
  - ស្រវឹង ឬវិកលចរិត (គ្មានអ្នកថែទាំ)
  - នាំសត្វចិញ្ចឹមគ្រប់ប្រភេទ ឬសាច់ឆៅដែលគ្មានការវេចខ្ចប់ត្រឹមត្រូវ
  - ជិះរថយន្តដោយគ្មានឯកសារបញ្ជាក់ ដូចជាសំបុត្របង់ប្រាក់ ឬឆ្លុតកាតអេឡិចត្រូនិច។

៩- ក្រុមហ៊ុនត្រូវរៀបចំបទបញ្ជា និងលក្ខខណ្ឌសម្រាប់បុគ្គលិកបម្រើសេវាលើរថយន្តដោយត្រូវបំពេញលក្ខខណ្ឌសារវន្តមួយចំនួនដូចខាងក្រោម៖

+ បុគ្គលិកផ្ដល់សេវាត្រូវ៖

- ជានីតិជនដែលត្រូវបានកំណត់ដោយច្បាប់ ដែលនៅជាធរមាន
- មានសុខភាពល្អ គ្មានជំងឺឆ្លង និងមានការត្រួតពិនិត្យសុខភាពតាមកាលកំណត់
- មានអត្តចរិតស្លូតបូត សុភាពរាបសារ និងរួសរាយរាក់ទាក់ចំពោះអតិថិជន
- មានឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនផ្លូវការរបស់ក្រុមហ៊ុន នៅពេលបំពេញការងារ

- រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងអនាម័យនៅលើរថយន្ត
- ចេះណែនាំដល់អ្នកដំណើរមិនឱ្យធ្វើសកម្មភាពណាមួយដែលអាចបង្កហានិភ័យដល់អ្នកដំណើរផ្សេងទៀត
- មានស្មារតីទទួលខុសត្រូវខ្ពស់ ចេះសម្របសម្រួល និងដោះស្រាយរាល់បញ្ហាចំពោះមុខដែលអាចនឹងកើតមានឡើងជាយថាហេតុ
- រក្សាទុករាល់សម្ភាររបស់អ្នកដំណើរដែលបានភ្លេចនៅលើរថយន្ត និងត្រូវប្រគល់សម្ភារទាំងនោះទៅទីស្នាក់ការកណ្តាលដើម្បីរង់ចាំប្រគល់ជូនម្ចាស់ដើមវិញ
- គោរពពេលវេលា និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

+ បុគ្គលិកផ្តល់សេវាមិនត្រូវ៖
- សេពគ្រឿងស្រវឹង ឬសារធាតុហាមឃាត់ណាមួយ ក្នុងពេលកំពុងបំពេញការងារ
- បង្កហេតុឬសកម្មភាពអវិជ្ជមានណាមួយដែលអាចនាំឱ្យប៉ះពាល់ដល់អ្នកធ្វើដំណើរនិងទ្រព្យសម្បត្តិរបស់អ្នកធ្វើដំណើរ
- រក្សាទុកនូវទំនិញគ្រោះថ្នាក់ អាវុធ ជាតិផ្ទុះ និងសារធាតុផ្សេងៗ ដែលច្បាប់បានហាមឃាត់
- ទាមទារតម្លៃសេវាដឹកជញ្ជូនលើសការកំណត់ក្នុងសៀវភៅប្រតិបត្តិការអាជីវកម្មនេះ
- ប្រព្រឹត្តិសកម្មភាពផ្សេងៗទៀត ដែលមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលនៅជាធរមាន។

+ បុគ្គលិកផ្តល់សេវាមានសិទ្ធិ៖
- ណែនាំដល់អ្នកដំណើរឱ្យរក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់នៅក្នុងរថយន្ត
- ហាមឃាត់អ្នកធ្វើដំណើរដែលមិនស្តាប់ ឬមិនអនុវត្តតាមការណែនាំ
- ហាមឃាត់អ្នកដំណើរដែលមានទង្វើផ្ទុយពីបទបញ្ជា ឬលក្ខខណ្ឌអនុញ្ញាត
- មិនអនុញ្ញាតឱ្យធ្វើដំណើរ នូវអ្នកដំណើរដែល៖
  - គ្មានសម្លៀកបំពាក់ ឬសម្លៀកបំពាក់មិនសមរម្យ
  - កុមារក្រោមអាយុ៦ឆ្នាំ (គ្មានអាណាព្យាបាលនៅជាមួយ)
  - ស្រវឹង ឬវិកលចរិត (គ្មានអ្នកថែទាំ)
  - នាំសត្វចិញ្ចឹមគ្រប់ប្រភេទ ឬសាច់ដៅដែលគ្មានការវេចខ្ចប់ត្រឹមត្រូវ
  - ជិះរថយន្តដោយគ្មានឯកសារបញ្ជាក់ ដូចជាសំបុត្របង់ប្រាក់ ឬឆ្លូតកាតអេឡិចត្រូនិច។

**១០-** ក្រុមហ៊ុនត្រូវរៀបចំបទបញ្ជានិងលក្ខខណ្ឌសម្រាប់គ្រប់គ្រងអ្នកដំណើរតាមរថយន្តក្រុង ដូចខាងក្រោម៖

+ អ្នកដំណើរត្រូវ៖
- តម្រង់ជួររង់ចាំនៅចំណតមុនពេលឡើងជិះរថយន្ត
- រក្សារបៀបរៀបរយ និងសុជីវធម៌នៅគ្រប់ពេលឡើងនិងចុះពីរថយន្ត
- ផ្តល់អាទិភាពឱ្យគ្នាទៅវិញទៅមក ពិសេសកុមារ ស្ត្រីមានផ្ទៃពោះ ជនពិការ និងចាស់ជរា
- ស្តាប់ការណែនាំរបស់អ្នកបើកបររថយន្ត និងបុគ្គលិកផ្តល់សេវាក្នុងរថយន្ត
- ស្តាប់ប្រកាសណែនាំនៅតាមបណ្តាលស្ថានីយ ឬចំណតរង់ចាំផ្សេងៗ
- ត្រូវបង្ហាញសំបុត្រ ឬបង់កម្រៃដឹកជញ្ជូនដល់អ្នកបើកបរឬបុគ្គលិកផ្តល់សេវាលើរថយន្ត ឬឆ្លូតកាតតាមឧបករណ៍អេឡិចត្រូនិច
- បង្ហាញលិខិតឬឯកសារពាក់ព័ន្ធ ក្នុងករណីមានកិច្ចព្រមព្រៀងជិះរថយន្តដោយមិនគិតថ្លៃ
- គោរពតាមការណែនាំរបស់អ្នកបើកបរ ក្នុងករណីមានរៀបចំផ្ទេរពីរថយន្តមួយទៅរថយន្តមួយទៀត ឬក្នុងករណីមានហេតុការណ៍ចាំបាច់ណាមួយកើតឡើង
- ចុះពីរថយន្តនៅចំណតចុងក្រោយបង្អស់
- សងរាល់ការខូចខាតដែលបង្កឡើងដោយទង្វើរបស់ខ្លួន ដល់អ្នកដំណើរផ្សេងទៀត ឬសម្ភារក្នុងរថយន្ត

- គោរពនិងអនុវត្តគោលការណ៍សំខាន់ៗផ្សេងទៀត ដែលមានកំណត់នៅក្នុងបទប្បញ្ញត្តិនៅជាធរមាន។

+ អ្នកដំណើរមិនត្រូវ៖

- បង្កភាពច្របូកច្របល់នៅគ្រប់ពេលឡើងជិះ និងចុះពីរថយន្ត
- ប្រជ្រៀតគ្នា ឬស្រែកឡូឡាបង្កជាជម្លោះនៅគ្រប់ពេលឡើងជិះ និងចុះពីរថយន្ត
- ប៉ះពាល់ឬធ្វើឱ្យខូចខាតនូវគ្រឿងសម្ភារបំពាក់លើរថយន្តនិងសម្ភារបម្រើសេវានានា
- សេពគ្រឿងស្រវឹងឬសារធាតុហាមឃាត់ នៅពេលកំពុងធ្វើដំណើរ
- ខាកស្តោះ បោលសម្រាម ឬកាកសំណល់ផ្សេងៗនៅក្នុងនិងក្រៅរថយន្ត នៅពេលធ្វើដំណើរ
- យកមកជាមួយនូវអាវុធជាតិផ្ទុះ វត្ថុងាយឆេះ ងាយបែក ជាតិពុល វត្ថុគ្រោះថ្នាក់ ឬវត្ថុមុតស្រួចដែលគ្មានការវេចខ្ចប់ត្រឹមត្រូវ ឬវត្ថុធ្វើឱ្យប៉ះពាល់ដល់អ្នកដំណើរផ្សេងទៀត
- ក្លែងបន្លំលិខិត ឬឯកសារធ្វើដំណើរ ដូចជាសំបុត្របង់កម្រៃសេវាដឹកជញ្ជូន។ អ្នកធ្វើដំណើរត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ពល់សកម្មភាពក្លែងបន្លំឯកសារ កោសកែប័ណ្ណនានា ឬកាន់ប័ណ្ណអ្នកដទៃ។

+ អ្នកដំណើរមានសិទ្ធិ៖

- រាយការណ៍ជូនទៅទីស្នាក់ការកណ្តាល ឬអ្នកគ្រប់គ្រងគ្រប់ស្ថានីយនូវរាល់ទង្វើខុសឆ្គងដែលអ្នកបើកបររថយន្ត ឬបុគ្គលិកផ្តល់សេវាលើរថយន្ត ឬបុគ្គលិកក្រុមហ៊ុនបានប្រព្រឹត្ត
- ប្តឹងទៅស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរដែនដីប្រសិនបើអ្នកដំណើរមិនព្រមទទួលយកដំណោះស្រាយដែលក្រុមហ៊ុនសម្រេច។

## ផ្នែកទី៣ ពេលវេលាប្រតិបត្តិការ

### ១១- ពេលវេលាប្រតិបត្តិការ

ក្រុមហ៊ុនត្រូវរៀបចំពេលវេលាប្រតិបត្តិការនៃសេវាដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង ដូចខាងក្រោម៖

- ៧ ថ្ងៃ ក្នុង ១ សប្តាហ៍ (ពីថ្ងៃ ចន្ទ ដល់ ថ្ងៃ អាទិត្យ រួមទាំងថ្ងៃឈប់សំរាកបុណ្យជាតិ និងអន្តរជាតិ)
- រយៈពេលប្រតិបត្តិការត្រូវចែកចេញជាវេនឱ្យសមស្របតាមតម្រូវការនៃការធ្វើដំណើររបស់ប្រជាពលរដ្ឋ
- រយៈពេលរង់ចាំរថយន្តក្រុង

  * <u>ម៉ោងមមាញឹក</u> : ( ១០-១៥នាទី /គ្រឿង )

    ចាប់ពីម៉ោង ៦:០០ ព្រឹក ដល់ ៨:០០ ព្រឹក

    ១៧:០០ ល្ងាច ដល់ ១៩:០០ យប់

  * <u>ម៉ោងធម្មតា</u> : ( ១៥នាទី ដល់ ២០នាទី / គ្រឿង)

ពេលវេលាប្រតិបត្តិការនេះអាចមានការប្រែប្រួលអាស្រ័យទៅលើស្ថានភាពជាក់ស្តែង និងតាមការជូនដំណឹងរបស់ក្រុមហ៊ុន។

## ផ្នែកទី៤ ខ្សែរត់ និងចំណត

### ១២- ខ្សែរត់

ក្រុមហ៊ុនត្រូវសហការរៀបចំជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ដោយត្រូវរៀបចំខ្សែរត់រថយន្តក្រុងរបស់ខ្លួនដូចខាងក្រោម៖

| ល.រ | បណ្តាញខ្សែរត់ | ចំណុចចាប់ផ្តើម | ផ្លូវធ្វើដំណើរ | ចំណុចគោលដៅ | ចម្ងាយផ្លូវ | ចំនួនរថយន្ត |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| សរុបរថយន្ត | | | | | | |

ខ្សែរត់នេះអាចត្រូវបានបន្ថែម ឬបន្ថយអាស្រ័យទៅតាមតម្រូវការជាក់ស្តែង តាមការស្នើសុំរបស់ក្រុមហ៊ុន និងបន្ទាប់ពីមានការឯកភាពពីអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

**១៣- ចំណត**

ក្រុមហ៊ុនត្រូវសហការរៀបចំនូវចំណតដូចខាងក្រោម៖

- ចំណតរង់ចាំ (Bus Stop)
  - ចំនួនប្រមាណ .... ចំណត លើកំណាត់ផ្លូវ...
  - ទំហំ ប្រមាណ ១០ម² ទៅ ១២ម² ឬតាមស្ថានភាពជាក់ស្តែង
  - មានជម្រក និងកន្លែងអង្គុយសមរម្យ
  - មានបំពាក់នូវភ្លើងបំភ្លឺ ស្លាកសញ្ញា ភ្លើងសញ្ញា និងតារាងផ្តល់ព័ត៌មានផ្សេងៗ
- ចំណតស្ថានីយចេញដំណើរ ឬមកដល់ ( Bus Terminal)
  - ចំនួនប្រមាណ ... ចំណត លើកំណាត់ផ្លូវ...
  - ក្នុងមួយខ្សែមាន ២ ស្ថានីយ (ស្ថានីយដើមទី និងចុងទី)
  - ទំហំ ប្រមាណ ២៥០ម² ក្នុង ១ ស្ថានីយ អាចផ្ទុករថយន្តប្រមាណពី ៣គ្រឿង ទៅ ៤គ្រឿង
  - មានជម្រក និងកន្លែងអង្គុយ បញ្ជរលក់សំបុត្រ និងបង្គន់អនាម័យ
  - មានបំពាក់នូវភ្លើងបំភ្លឺ ស្លាកសញ្ញា ភ្លើងសញ្ញា និងតារាងផ្តល់ព័ត៌មានផ្សេងៗ
- យានដ្ឋាន (Depot)
  - ចំនួន១ កន្លែងយ៉ាងតិច
  - មានបរិវេណគ្រប់គ្រាន់សម្រាប់ចតរថយន្ត
  - មានកន្លែងជួសជុល និងថែទាំរថយន្ត
  - មានកន្លែងត្រួតពិនិត្យ បំប៉នស្មារតី និងសម្រាករបស់អ្នកបើកបរ
  - មានការិយាល័យត្រួតពិនិត្យសកម្មភាពរថយន្តពេលធ្វើប្រតិបត្តិការ

## ផ្នែកទី៥ គោលនយោបាយ និងតម្លៃសំបុត្រ

**១៤- ប្រភេទសំបុត្រ**

ក្រុមហ៊ុនត្រូវរៀបចំសំបុត្ររថយន្តក្រុងទៅតាមប្រភេទ ដូចខាងក្រោម៖

- ប្រភេទសំបុត្រជាក្បាល
- ប្រភេទប័ណ្ណជិះប្រចាំខែ
- ប្រភេទប័ណ្ណ Prepaid Card ឬប្រភេទ **Electronic** ផ្សេងៗទៀត

**១៥- គោលនយោបាយសំបុត្រ**

ក្រុមហ៊ុនត្រូវរៀបចំគោលនយោបាយតម្លៃសំបុត្រជិះរថយន្តក្រុងដូចខាងក្រោម៖

- សំបុត្រធម្មតាសម្រាប់អ្នកដំណើរ ១ លើក ឬ ១ខែ ៣ខែ...
- ព្រះសង្ឃ សិស្ស និស្សិត ជនពិការ
- ជនចាស់ជរាមានអាយុចាប់ពី ៧០ឆ្នាំ ឡើងទៅ
- ក្មេងកម្ពស់ទាបជាង ០១ ម៉ែត្រ
- លក្ខខណ្ឌនៃការប្រើប្រាស់សំបុត្រ៖
  - សំបុត្រទិញហើយមិនអាចប្តូរវិញបាន
  - សំបុត្រមួយសន្លឹកជិះបានតែមួយលើក

- សំបុត្រមិនត្រូវដាច់ជាពីរ រហែក ឬកោសលុប
- សំបុត្រហាមមានការក្លែងបន្លំ

គោលនយោបាយតម្លៃសំបុត្រនេះអាចត្រូវបានកែប្រែទៅតាមស្ថានភាពជាក់ស្តែង តាមការស្នើសុំរបស់ក្រុមហ៊ុននិងបន្ទាប់ពីមានការឯកភាពពីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ១៦- តម្លៃសំបុត្រជិះរថយន្ត

ក្រុមហ៊ុនត្រូវរៀបចំតារាងតម្លៃសេវាដឹកជញ្ជូនអ្នកដំណើរដូចខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសំបុត្រ | កំណត់សម្គាល់ |
|---|---|---|---|
| | | គិតជារៀល | |
| ១ | **ប្រភេទសំបុត្រធម្មតា** | | |
| | រថយន្តប៊ីសធុនធំ | | |
| | រថយន្ត Mini Bus | | |
| ២ | **ប្រភេទសំបុត្រជាវជាក្បាល** | | |
| | រថយន្តប៊ីសធុនធំ | | |
| | រថយន្ត Mini Bus | | |
| ៣ | **ប្រភេទប័ណ្ណប្រចាំខែ** | | |
| | -ប្រភេទធម្មតា (Bus) | | |
| | -ប្រភេទពិសេស (Bus+Mini Bus) | | |
| ៤ | **ប្រភេទប័ណ្ណ Prepaid Card** | | |
| | រថយន្តប៊ីសធុនធំ | | |
| | រថយន្ត Mini Bus | | |

- ក្រុមហ៊ុនត្រូវរៀបចំតារាងតម្លៃសេវាដឹកជញ្ជូនអ្នកដំណើរ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកធ្វើដំណើរនិងហាមដាច់ខាតនូវការទារតម្លៃសេវាដឹកជញ្ជូនលើសការកំណត់ក្នុងតារាងតម្លៃនៃសៀវភៅប្រតិបត្តិការនេះ
- ករណីភ្នាក់ងាររបស់ក្រុមហ៊ុន ឬអ្នកបើកបររថយន្ត ឬបុគ្គលិកផ្តល់សេវាលើរថយន្តទារតម្លៃសេវាដឹកជញ្ជូនអ្នកដំណើរលើសពីការកំណត់នៃតារាងតម្លៃ ត្រូវទទួលវិន័យដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដែលនៅជាធរមាន

១៧- ក្រុមហ៊ុនត្រូវសហការរៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយ និងជូនដំណឹងដល់សាធារណជនឱ្យយល់ដឹងអំពីការផ្តល់សេវាដឹកជញ្ជូនសាធារណៈដោយរថយន្តក្រុង តាមគ្រប់មធ្យោបាយដូចជា វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ដែលទទួលស្គាល់ដោយអាជ្ញាធរស្របច្បាប់។

# ផ្នែកទី៦ ការជួសជុល ថែទាំទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារ

## ១៨- ការថែទាំ និងជួសជុល

ក្រុមហ៊ុនត្រូវរៀបចំនូវកាលវិភាគជាក់លាក់មួយជាប្រចាំសម្រាប់តាមដាន និងធ្វើការជួសជុលថែទាំនូវទ្រព្យសម្បត្តិដូចខាងក្រោម៖

- ការជួសជុលថែទាំយានយន្ត
- ការជួសជុលថែទាំយានដ្ឋាន

- ការជួសជុលថែទាំចំណត និងផ្លាកសញ្ញា
- ការជួសជុលថែទាំគ្រប់ស្ថានីយ និងគ្រឿងបរិក្ខារផ្សេងៗ

## ជំពូក ៣
## ការត្រួតពិនិត្យ និងការគ្រប់គ្រង
### ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**១៩-** ក្រុមហ៊ុនត្រូវរាយការណ៍ពីស្ថានភាពគ្រប់គ្រងរបស់ខ្លួនជូនអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកស្តីពីអាជីវកម្មផ្ទាល់ខ្លួននូវព័ត៌មានដូចខាងក្រោម៖

- ស្ថិតិអ្នកធ្វើដំណើរ
- ប្រសិទ្ធភាពនៃការផ្តល់សេវា
- របាយការណ៍ពីបាតុភាពដែលបង្កដោយអ្នកធ្វើដំណើរ និងព្រឹត្តិការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់ក្រុមហ៊ុន
- សំណូមពរ និងការផ្តល់ជូន
- វិវាទផ្សេងៗ និងដំណោះស្រាយ។

### ផ្នែកទី ២ ការទទួលខុសត្រូវរបស់ក្រុមហ៊ុន

**២០-** ក្រុមហ៊ុនត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្មដែលកើតមានឡើងក្នុងការប្រតិបត្តិការបេសកកម្មដែលបានប្រគល់ជូន។ ព្យសនកម្មឬផលប៉ះពាល់ដែលកើតមានឡើងក្នុងការប្រតិបត្តិការបេសកកម្មមានជាអាទិ៍៖

- ការប៉ះពាល់ដល់និរន្តរភាពសេវាសាធារណៈ ការប៉ះពាល់យ៉ាងធ្ងន់ដល់ផលប្រយោជន៍របស់អ្នកធ្វើដំណើរ ឬប្រយោជន៍សាធារណៈជន ឬទ្រព្យសម្បត្តិសាធារណៈ
- ការមិនគោរពកាតព្វកិច្ចដូចបានកំណត់ក្នុងសៀវភៅប្រតិបត្តិការនេះ
- ការមិនផ្តល់សេវា ការផ្តល់សេវាយឺត ឬមិនគ្រប់ជ្រុងជ្រោយ
- ការធ្វេសប្រហែសក្នុងការផ្តល់សេវាមិនបានល្អ
- ការលួច ការឆបោក ឬការកេងបន្លំលើអាជីវកម្ម។

## ជំពូក ៤
## ការដោះស្រាយវិវាទ

**២១-** ក្នុងករណីមានវិវាទរវាងក្រុមហ៊ុននិងអ្នកធ្វើដំណើរ ឬរវាងអ្នកធ្វើដំណើរនិងអ្នកធ្វើដំណើរ ត្រូវអនុវត្តយន្តការសម្រាប់ការដោះស្រាយជា ៤ (បួន) ដំណាក់កាល៖

១/ ដោយការសម្រុះសម្រួលគ្នានៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន
២/ ដោយមានការចូលរួមសម្រុះសម្រួលពីអ្នកជំនាញច្បាប់ នៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន
៣/ ដោយមានការចូលរួមពីស្ថាប័នមានសមត្ថកិច្ច
៤/ ប្តឹងទៅតុលាការតាមផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូក ៥
## អវសានបញ្ញត្តិ

**២២-** សៀវភៅប្រតិបត្តិការអាជីវកម្មនេះត្រូវចុះហត្ថលេខាដោយម្ចាស់ក្រុមហ៊ុន ឬអ្នកតំណាងស្របច្បាប់ ព្រមទាំងមានការពិនិត្យឯកភាពពីអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

២៣- សៀវភៅប្រតិបត្តិការអាជីវកម្មនេះ មានសុពលភាពរហូតដល់មានការអនុម័តសៀវភៅប្រតិបត្តិការអាជីវកម្មថ្មី។

២៤- ក្នុងករណីមានការរំសាយឬបញ្ឈប់ប្រតិបត្តិការអាជីវកម្ម ក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនមកអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក។

សៀវភៅប្រតិបត្តិការអាជីវកម្មនេះធ្វើឡើងចំនួន ០៥ ច្បាប់ ជាភាសាខ្មែរតម្កល់ទុកនៅ៖

| | |
|---|---|
| ១- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | ០១ ច្បាប់ |
| ២- សាលារាជធានី ខេត្ត | ០១ ច្បាប់ |
| ៣- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត | ០១ ច្បាប់ |
| ៤- ក្រុមហ៊ុន | ០១ ច្បាប់ |
| ៥- កាលប្បវត្តិ | ០១ ច្បាប់ |

ថ្ងៃ..................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ ............ឆ្នាំ ២០១...

**ក្រុមហ៊ុន**

**បានឃើញនិងពិនិត្យត្រឹមត្រូវ**

ថ្ងៃ..................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ ............ឆ្នាំ២០១...

**នាយកដ្ឋានដឹកជញ្ជូនសាធារណៈគ្រុង**

លេខ.........................

**បានឃើញនិងឯកភាព**

ថ្ងៃ..................ខែ...........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី...........ខែ ............ឆ្នាំ ២០១...

**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**

# ឧបសម្ព័ន្ធទី២

## គំនូសបំព្រួញអំពីដំណើរការផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ តាមរថយន្តក្រុង

យោងប្រកាសលេខ...................... ចុះថ្ងៃទី......... ខែ.......... ឆ្នាំ...............
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គល
ធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង




**សម្គាល់៖**

ប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំលិខិតអនុញ្ញាតឱ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ តាមរថយន្តក្រុង មានគេហទំព័រ transportlicense.mpwt.gov.kh

## ឧបសម្ព័ន្ធទី៣

ទម្រង់ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ
តាមរថយន្តក្រុង

យោងប្រកាសលេខ...................... ចុះថ្ងៃទី......... ខែ.......... ឆ្នាំ...............
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គល
ធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំវិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ
## តាមរថយន្តក្រុង

គោត្តនាម និងនាម.........................................................ភេទ.................សញ្ជាតិ.....................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន.........................
ក្រុមហ៊ុននាម.........................................................................................................................
អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ...............ផ្លូវ...............ភូមិ.......................សង្កាត់/ឃុំ...................
ខណ្ឌ/ស្រុក/ក្រុង...........................រាជធានី/ខេត្ត..............................លេខទូរស័ព្ទ.......................
អ៊ីម៉ែល....................................... កម្មវត្ថុអាជីវកម្ម.................................................................។

ធ្វើនៅ.....................ថ្ងៃទី.......ខែ...........ឆ្នាំ..............

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ឯកសារភ្ជាប់៖**

- អត្តសញ្ញាណរបស់នីតិបុគ្គល៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ករណីក្រុមហ៊ុនសញ្ជាតិខ្មែរ)
  - លិខិតឆ្លងដែន (ករណីក្រុមហ៊ុនសញ្ជាតិបរទេស)
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លក្ខន្តិកៈក្រុមហ៊ុន
- ប័ណ្ណប៉ាតង់
- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត(ដេប៉ូ)
- តារាងស្ថិតិយានយន្ត (ភ្ជាប់លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ)

## ឧបសម្ព័ន្ធទី៤

ទម្រង់ពាក្យសុំលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ
តាមរថយន្តក្រុង

យោងប្រកាសលេខ...................... ចុះថ្ងៃទី......... ខែ.......... ឆ្នាំ..............
ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គល
ធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ តាមរថយន្តក្រុង

គោត្តនាម និងនាម........................................................................ភេទ...............សញ្ជាតិ...........................
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន.......................
មានក្រុមហ៊ុននាម..............................................................................................................................
អាសយដ្ឋានបច្ចុប្បន្ន -ផ្ទះលេខ...............ផ្លូវ...............ភូមិ.....................សង្កាត់/ឃុំ...................
ខណ្ឌ/ស្រុក/ក្រុង...........................រាជធានី/ខេត្ត...........................លេខទូរស័ព្ទ..........................
អ៊ីម៉ែល.................................... កម្មវត្ថុអាជីវកម្ម.......................................................................
លើតម្រាយខ្សែរត់.............................................................................................................................

ធ្វើនៅ....................ថ្ងៃទី......ខែ...........ឆ្នាំ.............

**ហត្ថលេខា និងត្រាក្រុមហ៊ុន**

**ឯកសារភ្ជាប់៖**

- អត្តសញ្ញាណរបស់នីតិបុគ្គល៖
  - ○ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (ករណីក្រុមហ៊ុនសញ្ជាតិខ្មែរ)
  - ○ លិខិតឆ្លងដែន (ករណីក្រុមហ៊ុនសញ្ជាតិបរទេស)
- វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម
- សៀវភៅប្រតិបត្តិការអាជីវកម្ម
- ប័ណ្ណប៉ាតង់
- លិខិតបញ្ជាក់ទីតាំងចំណតរថយន្ត(ដេប៉ូ)
- តារាងស្ថិតិយានយន្ត (ភ្ជាប់លិខិតអនុញ្ញាតឱ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
លេខ(No)៖..........................................

# វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង
## LICENSE OF PUBLIC BUS OPERATION SERVICES

នាមករណ៍ក្រុមហ៊ុន..........................................................................................
ចុះបញ្ជីលេខ.......................................................ចុះថ្ងៃទី..........ខែ..............ឆ្នាំ....................
អាសយដ្ឋាន ..........................................................................................

Company name..........................................................................................
Registration Number.......................................Date..........................................
Address..........................................................................................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this License

**សម្គាល់៖** វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង មានទំហំ A4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងសាធារណការ និងដឹកជញ្ជូន
MINISTRY OF PUBLIC WORKS AND TRANSPORT
អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក
GENERAL DEPARTMENT OF LAND TRANSPORT

លេខ(No)៖..........................................

# លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង
## PERMIT OF PUBLIC BUS OPERATION SERVICES

នាមករណ៍ក្រុមហ៊ុន..........................................................................................................................

វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនលេខ..............................ចុះថ្ងៃទី..........ខែ...............ឆ្នាំ...................

កម្មវត្ថុអាជីវកម្ម...................................................................................លើខ្សែរត់.......................................

អាសយដ្ឋាន ..........................................................................................................................

កាលបរិច្ឆេទចេញ..................................កាលបរិច្ឆេទផុតសុពលភាព.........................................។

Company name..........................................................................................................................

Registration Number.........................................................Date.........................................................

Business Objective...................................................................................On Line........................................

Address..........................................................................................................................

Date of Issue...............................................Date of Expiry...................................................

លិខិតអនុញ្ញាតនេះ មិនចាំបាច់មានហត្ថលេខា
The Signature is not required in this License

សម្គាល់៖ លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង មានទំហំ A4

# ឧបសម្ព័ន្ធទី៥

ទម្រង់របាយការណ៍អំពីទិន្នផលដឹកជញ្ជូន

ប្រកាសលេខ...................... ចុះថ្ងៃទី.........ខែ.............ឆ្នាំ..................

ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យនីតិបុគ្គល

ធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

ដែលត្រូវបោះពុម្ពចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្មស្នើសុំធ្វើអាជីវកម្មដឹកជញ្ជូនសាធារណៈ

តាមរថយន្តក្រុងដោយមានទិន្នន័យភ្ជាប់មកជាមួយស្រាប់

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុនៈ**..................................................................................................................

**លេខលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើអាជីវកម្ម ៖**..........................................................................

### របាយការណ៍អំពីទិន្នផលដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង

| លរ. | ចំនួនយានយន្ត (A) | ចំនួនកៅអី(នាក់) (B) | សរុបចំនួនអ្នកដំណើរ(នាក់) (ជាក់ស្តែង) (C)=(A)x (B) | ទិសដៅ | សេចក្តីបញ្ជាក់ផ្សេងៗ |
|---|---|---|---|---|---|
| ១<br>២<br>៣<br>. | | | | | |